ការសំភាសន៍របស់លោកពូ ចិន ចយ

កៈ អ្នកដែលសំភាសន៍ ញ៉ែម សុគន្ធា ខៈ អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ចិន ចយ

ជីវប្រវត្តិសង្ខេបសំភាសន៍របស់លោកពូ ចិន ចយ

លោកពូមានប្អូន៥នាក់ ហើយលោកពូចិន ចយគឺជាបងគេ
នៅក្នុងប្រវត្តិរបស់គាត់នៅលោកពូបានប្រាប់ពីប្រវត្តិដូនតាថាលោកតារបស់គាត់បានមកពី
ខេត្តពោធិ៍សាត់ ហើយបានមកស្តីដណ្តឹងលោកយាយហើយបានជិះដំរីមក
ហើយនេះពិតជាអស្ចារ្យសំរាប់មនុស្សជំនាន់ពីដើម
។ម្តាយឪពុកលោកពូស្រលាញ់កូនស្មើៗគ្នាហើយបានចែកកេរ្តិ៍អាករអោយកូនស្មើៗគ្នា
។លោកប៉ារបស់លោកពូគាត់បានធ្វើរបរស្រែចំការដើម្បីចិញ្ចឹមកូននឹងរត់កង់ឌុបផងដែរដោយ
សារជំនាន់ពេលទឹមបែកសង្គ្រាមគឺគ្មានម៉ូតូទេមានតែកង់ឌុប។
ហើយលោកពូក៏ជាអ្នកនេសាទសំរាប់រកស៊ីចិញ្ចឹមកូនផងដែរ។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់លោកពូដែលអោយញ៉ែមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូ នាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូនៅក្នុងថ្ងៃនេះ ហើយទីតាំងដែលយើងសំភាសន៍នៅបឹតនៅក្នុងភូមិកោះគរ ឃុំកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ប្រទេសកម្ពុជា អ៊ីចឹងថ្ងៃដែលពួកយើងសំភាសន៍គឺនៅក្នុងនៅក្នុងខែ កុម្ភៈ ឆ្នាំ២០១៨
អ៊ីចឹងខ្ញុំសូមចាប់ផ្តើមសំភាសន៍អំពីជីវប្រវត្តិរបស់លោកពូនៅក្នុងថ្ងៃនេះតែម្តង
អ៊ីចឹងលោកពូអាចរៀបរាប់អំពីជីវិតក៏ដូចជាអ្វីដែលញ៉ែមបានសួរលោកពូក៏ដូចជាអ្វីដែលលោកពូចង់និយាយប្រាប់ពីជីវិតអ៊ីចឹងហាលោកពូទៅកាន់កូនចៅជំនាន់ក្រោយទុកអោយគាត់ស្តាប់
អ៊ីចឹងហ៊ាពូ!!ខះបាទ!!កៈអ៊ីចឹងលោកពួសូមប្រាប់ឈ្មោះពេញរបស់លោកពូ?

ខៈខ្ញុំឈ្មោះ ចិន ចយ។

កៈអ៊ីចឹងលោកពូសំរាប់ក្រៅពីឈ្មោះលោកពូចិន ចយ
តើលោកពូមានឈ្មោះអីហៅខាងក្រៅទៀតអត់?

ខៈក្មានទេមានតែឈ្មោះមួយហ្នឹង។

កៈពីក្មេងមកមានឪពុកម្តាយឬក៏បងប្អូនអីជិតខាងមានអ្នកណាគេហៅអីរហ័សនាមអីទេ?

ខៈអត់មានផង។

កៈដោយសារខ្មែរយើង!!

ខៈហេនៅពីក្មេងគេហៅញ៉ែមអាម៉ាប់ៗ
កាលមុនញ៉ែមធាត់!!កៈហ្ហ!!ខៈកាលពីនេះញ៉ែមធាត់កាលពីតូចហ៊ា!!កៈចំ!!ខៈគេហៅញ៉ែមអាកាម៉ាប់ កាម៉ាប់អ៊ុចឹងទៅ។

កៈហ្នឹងហើយ
អ៊ុចឹងមានឈ្មោះម៉ាប់ទៀត។ចាំអ៊ុចឹងលោកពូសំរាប់អើរលោកពូសព្វថ្ងៃអាយុប៉ុន្មានហើយ។

ខៈ៤៥ ៤៤ ៤៥ !!

កៈ៤៤ !!

ខៈហ្នឹងហើយ។

កៈចាំ!!អ៊ុចឹងលោកពូកើតថ្ងៃខែឆ្នាំកំនើតកើតនៅថ្ងៃខែឆ្នាំណា?

ខៈឆ្នាំ១៩៧២។

កៈចាំ តែអ្នកមីងមិនមែន៧៣ទេណោះ?

ខៈហ្នឹងហើយ!!

(ប្រពន្ធរបស់លោកពូ)៖ ញ៉ែមអញ្ចេះទេ ដាក់ដំឡើង ញ៉ែមដាក់ដំឡើង !!

កៈដំឡើងអាយុ?

(ប្រពន្ធរបស់លោកពូ)៖ញ៉ែមដំឡើងអាយុទេ។

កៈពូហើយមីងបងប្អូនគ្នាប៉ុន្មាន?

(ប្រពន្ធរបស់លោកពូ)៖បើអាយុញ៉ែមពិតវិញញ៉ែមកើត៧០(១៩៧០)។

ខៈគាត់ត្រូវបងញ៉ែម។

កៈប្រពន្ធលោកពូ១៩៧០គត់ទេ?

(ប្រពន្ធរបស់លោកពូ)៖ហ្នឹងហើយ។ដាក់ក្តងនេះញ៉ែមដាក់ដំឡើងញ៉ែមចូលធ្វើការហ៊ា!!

កៈចាំ!!អញ្ចឹងទៀត!!

(ប្រពន្ធរបស់លោកពូ)៖ហ្នឹង។

កៈលោកពូនិយាយថ្ងៃខែឆ្នាំកំនើតលោកពូអោយពេញមើល??ថ្ងៃណាខែណាឆ្នាំណា?

ខៈថ្ងៃណាខែណា!!

កៈអើរមើលនៅក្តងសំបុត្រកំនើតមើល!!

ខៈថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧២។

កៈចាំអ៊ុចឹងលោកពូទីកន្លែងកំណើតនៅភូមិឃុំអីគេដែរ?

ខៈភូមិកោះគរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល ។

កៈអ៊ុចឹងពូកើតនៅក្នុងភូមិឃុំដែលរស់នៅសព្វថ្ងៃហ្នឹងតែម្តង?

ខៈនេះមិនមែនទេ កាលញ៉ុមកើតញ៉ុមកើតនៅសំប៉ានណោះទេ គ្រាន់ថាអានេះគេដាក់នៅក្នុងស្រុកភូមិយើងហើយ យើងរស់នៅហ្នឹង។កៈហ្ន៎!!ខៈហ្នឹងហើយ។

កៈអ៊ុចឹងឥឡូវទីកន្លែងកំណើតដែលពូកើតគេហៅភូមិឃុំអីគេដែរ?

ខៈនៅសំប៉ាន គេកាលហ្នឹងជំនាន់ប៉ុល ពតគេជំលៀសទៅគាត់ថាកើតនៅវត្តសំប៉ានហ្នឹងនៅជិតកោះធំហ្ន៎។

កៈចំាវត្តសំប៉ាន ញ៉ុមធ្លាប់ស្គាល់វត្តហ្នឹងពូ!!

ខៈហ្នឹងហើយ វត្តសំប៉ានយើងទៅហ្នឹងនៅជិតវត្តទួលរាជាខាងកើតហ្នឹង!!

កៈហ្ន៎ហ្ន៎!!ហ្នឹងស្គាល់ហើយ។តែហ្នឹងគេហៅស្រុកកោះធំហើយវិញហេពូហី?

ខៈបាទហ្នឹងហើយ ស្រុកកោះធំ។

កៈខេត្តកណ្តាលហ្នឹង។

ខៈបាទហ្នឹងហើយ។

កៈចំាហ្នឹងទីកន្លែងដែលពូកើតពិត!!ខៈបាទ!!កៈអ៊ុចឹងពូសំរាប់ឆ្នាំខ្មែរវិញពូកើតឆ្នាំអីគេវិញ?

ខៈឆ្នាំជូត។

កៈឆ្នាំជូត។មីងឆ្នាំច ពូឆ្នាំជូត។

ខៈឆ្នាំកណ្តារ។

(ប្រពន្ធរបស់លោកពូ)៖ញ៉ុមដាក់ ញ៉ុមដាក់៧៣(១៩៧៣)នេះញ៉ុមដាក់បន្តយអាយុញ៉ុមចូលធ្វើការ។

កៈចំាហ្នឹងហើយ។អ៊ុចឹងមីញលោកពូកើតខែសីហាណោះ?ខៈបាទ!!កៈគេហៅឆ្នាំខ្មែរហាគេហៅខែខ្មែរគេហៅខែអីវិញទៅពូអាហ្នឹង?

ខៈមិនដឹងគេថាម៉េចហ្ន៎!!

កៈអត់ដឹងដែរហេ?អត់អីទេអ៊ុចឹង!!ចំាអ៊ុចឹងលោកពូសំរាប់ចូលដល់សមាជិកក្រុមគ្រួសាររបស់ពូវិញ ពូកើតមកមានបងប្អូនប្រុសស្រីប៉ុន្មាននាក់ដែរ?

ខៈបងប្អូន ប្រុស៤នាក់ស្រី១ម្នាក់ដែរ។

កៈចំា!!លោកពូអារៀបរាប់ឈ្មោះតាំងពីបងគេរហូតដល់ពៅគេហ៎ា??

ខៈញ៉ុមបងគេ។

កៈចំាអ៊ុចឹងឈ្មោះ!!អ៊ុចឹងពូបងគេ?ខៈបាទ!!កៈអ៊ុចឹងឈ្មោះទីមួយអីគេដល់ពៅគេហ៎ា!!រៀបរាប់ទាំងត្រកូលមកហ៎ា??

ខ:ញ៉ាមបងគេឈ្មោះចិន ចយ ហើយបបន្ទាប់មក ចិន ជួន !!ចិន ជួន ចិន គន្ធា ចិន សែន ចិន សៃ ៥នាក់។

ក:ចំាស្រីតែមួយទេពូណោះ?

ខ:ស្រីតែមួយ។

ក:ចំាហ្នឹងហើយ!!អ៊ីចឹងពូសំរាប់បងប្អូនទាំងអស់លោកពូស្រលាញ់មួយណាជាងគេ?

ខ:ញ៉ាមស្រលាញ់ទាំងអស់គ្នា ជាគ្រួសារទៅហើយ។

ក:ចំាហ្នឹងហើយ
អ៊ីចឹងលោកពូសំរាប់បងប្អូនរបស់លោកពូអនុស្សាវរីយ៍ដែលពួកគាត់មានជាមួយលោកពូ
ពូធ្លាប់លេងអីគេខ្លះជាមួយគាត់ហើយស្រលាញ់កន្លែងចំនុចណាសំរាប់ពួកគាត់អ៊ីចឹងហ៊ា!!

ខ:និយាយម្តងទៀត!!

ក:និយាយទៅអនុស្សាវរីយ៍ដែលពូធ្លាប់លេងជាមួយអើរបងប្អូនអ៊ីចឹងហ៊ា!!ខ:បាទ!ក:ចំាម៉េចដែរ?ចាំអនុស្សាវរីយ៍អីក្មេងៗធ្លាប់លេងអីជាមួយគ្នាខ្លះអត់ពូ?

ខ:អត់ អត់ចាំផងអ្នកក្រូ។

ក:អត់ចាំទេហេ?

ខ:បាទ!!

ក:ចុះពេលនេះនៅពីក្មេងធ្លាប់លេងដូចរបៀបថាទៅធ្វើស្រែធ្វើអីជាមួយគ្នាអើអត់?

ខ:ហ្គំបើធ្វើស្រែធ្វើអីធ្លាប់ទៅហ្នឹងហើយ។

ក:ម៉េចដែរពូពេលទៅជាមួយគ្នាសកម្មភាពដែលធ្វើម៉េចដែរ?

ខ:មានអីគាត់ជួយ។

ក:ថានីយាយទៅចរិកបងប្អូនរបស់លោកពូគាត់ម៉េចដែរពូអាចប្រាប់?

ខ:មានអីគាត់សួតបូតមានអីអត់មានកោងកាចអីផងគាត់មានអីគាតល្អ។

ក:អ៊ីចឹងពួកគាត់នៅរាល់ថ្ងៃហ្នឹងពួកគាត់នៅក្នុងភូមិឃុំនឹងដែរឬក៏គាត់នៅកន្លែងណាផ្សេង?

ខ:គាត់នៅភូមិឃុំហ្នឹងជាមួយគ្នាទាំងអស់!!ក:ចំា!!ខ:អត់ទៅណាទេ!!

ក:ចំាពូជួន ពូជួននៅខាងក្រោយហេ??

ខ:ពូជួនហ្នឹងហើយ!!

ក:ហ្នឹងហើយអូខេ!!

ខ:ប៉ុនគាត់នៅហូបស្រាបន្តិច គាត់និយាយអត់ស្តាប់ទេ!!

ក:តែពួកគាតទៅធ្វើការនៅថៃដែរពូហេ??

ខ:បាទ!!ហ្នឹងហើយ!!

ក:ទៅពូជួនមួយ។

ខ:តែមួយហ្នឹងហូបស្រា ក្រៅពីហ្នឹងល្អទាំងអស់ បងប្អូនញ៉ាំម។

ក:តែពូជួនមុខអត់សូវដូចពូផង!!

ខ:ហ្នឹងហើយ។

ក:មុនអត់ដូចគ្នាបងប្អូន។

ខ:ហ្នឹងហើយ។

ក:អ៊ីចឹងលោកពូការធំធាត់រស់នៅមកមកជាមួយគ្នាតើពួកគាតអើរភាគច្រើនពួកគាត់ប្រកបរបរអីគេដែរសំរាប់ចិញ្ចឹមជីវិតហ៊ា??

ខ:គាត់ប្រកបមុខរបរ??ក:ចា៎!!ខ:គាត់ ពួកគាត់មែន?

ក:ហ្នឹងហើយពួកគាត់ប្អូនពូហ្នឹងហា!!

ខ:គាត់រត់កង់ពរកម៉ូតូរកអីដូចញ៉ាំមដែរហ្នឹង!!ក:ចា៎!!ខ:ហ្នឹងហើយ!!

ក:នៅពីក្មេងឡើយប្អូនៗពូចូលចិត្តលេងអីគេច្រើនជាងគេដែលពូលេងជាមួយអ៊ីចឹងហ៊ា??គប់រង់ ដែលគប់រង់លេងជាមួយគ្នាទេ??

ខ:អើរអត់ដែលផង
ក្មេងៗគេលេងជាមួយគ្នាញ៉ាំមអត់ដល់ធំហើយវានៅក្មេងវានៅលេងជាមួយក្មេងៗអ៊ុចឹងទៅ ។ក:ចា៎!!ខ:អ៊ុចឹងអត់លេងជាមួយអត់លេងដូចក្មេងទេ!!

ក:ហ្នឹងហើយ ។

ខ:អត់ដែល។

ក:ភាគច្រើនឪពុកម្តាយរបស់ពូគាត់មានដែលអោយពូនៅមើលប្អូនឬក៏ឃុំក្រែងពួកគាត់ទេម៉េចទេ?

ខ:គាត់អោយមើលដែរ !!ក:ចា៎!!ខ:ហ្នឹងដល់ពេលគាត់ចេញទៅរកស៊ីអីមើលប្អូនមើលអីអ៊ុចឹងទៅ!!

ក:ចា៎ហើយពួកគាត់ត្រូវមានត្រូវទៅរៀនទៅអីអត់អ៊ុចឹង?

ខ:គាត់រៀនតើ!!

កៈទាំង៤ទាំង៥នាក់គាត់បានរៀនទាំងអស់ពូហេ?

ខៈបាទបានរៀនទាំងអស់គ្នា។កៈចំ!!!ខៈបាទ!!

កៈហ្នឹងហើយ
អ៊ុចឹងល្អណាស់ពូជំនាន់ពេលមុនក៏បានរៀន!!ខៈបាទ!!កៈពី៨០ជាង(១៩៨០)មកឬករៀនជំនាន់មុនសង្គ្រាមពូពេលរៀន?

ខៈកាលគាត់រៀននៅជំនាន់យើងនេះបែកហើយហ្នឹង!!

កៈបែកហើយបានរៀនហ្នឹងហេ?ខៈបាទ!!កៈពៅគេអាយុប៉ុន្មានវិញពូប្អូន?

ខៈពៅគេសែប្រហែលជា២៥ឆ្នាំអីហើយ!!

កៈចំ!!ខៈបាទ!!កៈហ៊ីទឹមតែ២៥ទេ??

ខៈ២៥។

កៈក្មេងហ្នឹងក្មេងជាងញ៉ុមទៀត!!

ខៈក្មេងនេះផ្ទះគៀននេះ!!

កៈហ្អ!!ហ្នឹងហើយអូខេ
អ៊ុចឹងលោកពូសំរាប់មិញបងប្អូនពូបាននិយាយប្រាប់ហើយមានអីចង់និយាយប្រាប់ពីបងប្អូនពូទេ??

ខៈនិយាយប្រាប់!!

កៈប្រាប់ពីអីក៏បានដែរពីបងប្អូនអ៊ុចឹងទៅណាស់??

ខៈអត់ទេ!!

កៈអស់ហើយហេ??ឥឡូវចូលដល់នេះម្តងឪពុកម្តាយវិញឥលូវចូលដល់ឪពុកមុន
តើឪពុកលោកពូគាត់ឈ្មោះអីគេដែរ?

ខៈគាត់ឈ្មោះ ហម ចិន។

កៈហម ចិន!!ខៈបាទ!!កៈចំាអ៊ុចឹងចុះសំរាប់ឪពុករបស់លោកពូឥលូវគាត់នៅរស់ដល់សព្វថ្ងៃទេ??

ខៈនៅរស់ដល់សព្វថ្ងៃ នៅរស់តើ!!

កៈចំ!!គាត់នៅឯណាវិញឥលូវពូ?

ខៈគាត់នៅវត្តឈូងលៀបគាត់ធ្វើជាអាចារ្យ។

កៈប៉ាធ្វើជាអាចារ្យតែកូនកាន់សាសនាគ្រីស្ទ!!

ខៈកូនកាន់យេស៊ូវ បាទ!!

កៈអូខេអត់អីទេពូមនុស្សមានការជ្រើសរើស តែគាត់អត់មានហាមឃាត់អីដែរពូណោះ??

ខៈគាត់អត់មានហាមឃាត់អីទេ ចុះជាសេចក្តីល្អទាំងអស់គ្នា!!កៈថា!!ខៈប៉ុន្តែគ្រាន់ថាវាអត់គិតខាងណោះហ៎ា!!កៈថា!!ហ្នឹងហើយ!!ខៈវាអត់មានពិតប្រាកដ ។

កៈថាដោយសារយើងស្គាល់សេចក្តីពិតហើយ។

ខៈវាអត់មានវិញ្ញាណបរិសុទ្ធដូចព្រះអង្គយើង។

កៈថាអ៊ុចឹងលោកពូដឹងថាឪពុកលោកពូគាត់កើតឆ្នាំខ្មែរគាត់កើតឆ្នាំអីគេទេ?

ខៈគាត់ឆ្នាំអីគេទេនេះ!!

កៈជូត ឆ្លូវ ខាល ថោះ ហ្គ៎??

(ប្រពន្ធរបស់លោកពូ)៖គាត់ឆ្នាំខាលហ្គ៎!!

ខៈហ្នឹងហើយ ដឹងថាគាត់ឆ្នាំខាល គាត់កើតឆ្នាំខាល។

កៈឆ្នាំខាលសត្វខ្លា។ខៈបាទ!!កៈថា!!អ៊ុចឹងសំរាប់លោកពូ
លោកប៉ារបស់លោកពូគាត់គាត់កើតថ្ងៃខែឆ្នាំណាដែរពូអាចមើលនៅក្នុងសំបុត្រកំណើតហ៎ា?

ខៈមាន!!

កៈថាមាននេះឪពុកខាងនេះ!!ហម ចិន។

ខៈហម ចិន !!ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៥០។

កៈឪពុកពូគាត់ដូចជាអត់រៀងសូវចាស់ណាប៉ុន្មានគាត់ទឹម៦០ជាងហ្នឹងហ៎ៅ?

ខៈបាទហ្នឹងហើយ៦០ជាង។

កៈថា!!ទីកន្លែងកំនើតគាត់ឪពុកពូនៅឯណាវិញ?

ខៈទីកន្លែងកំណើតគាត់កើតកាត់កើតនៅភូមិកោះគរ ឃុំរកាខ្ពស់!!

កៈ ស្រុកស្អាង ខេត្តកណ្តាល នៅហ្នឹងម៉ងហេ??

ខៈហ្នឹងហើយនៅហ្នឹង!!

កៈស្រុកកំណើតរបស់គាត់។

ខៈហេ ភូមិកោះគរ ឃុំរកាខ្ពស់!ហេភូមិព្រែកខ្សេរ ភូមិព្រែកខ្សេរ!!

កៈព្រែកខ្សេរអាហ្នឹងរបស់ម៉ែទេ!!

ខៈរបស់ម៉ែ??

កះហ្នឹងហើយរបស់ប៉ាតែត្រឹមនេះទេ(មើលក្នុងសំបុត្រកំនើត)។

ខះត្រឹមនេះទេ!!

កះហ្នឹងហើយ
ចុះលោកពូសំរាប់អើរឪពុករបស់លោកពូហាលោកពូធ្លាប់មានអនុស្សាវរីយ៍អីគេខ្លះជាមួយគាត់ក៏ដូចជាចរិកប៉ារបស់ពូគាត់ម៉េចដែរទៅ??ពូអាចរៀបរាប់ពីចរិករបស់គាត់អ៊ុចឹងហ៊ា??

ខះគាត់មានអីគេស្លូតបូត។កះច៉ា!!ខះប៉ុន្តែកាលពីដំបូងឡើយគាត់អាត់ទាន់បាន
គាត់កាលជំនាន់ហ្នឹងគាត់នៅក្នុងរដ្ឋកម្ពុជាគាត់ធ្លាប់ធ្វើជាសេនាជនដែរគាត់ហូបស្រាហូបអី
គាត់ខូចដែរកាល់ហ្នឹង ជំនាន់ហ្នឹងហា តលូវគាត់កែប្រែគាត់ គាត់កែប្រែគាត់
គាត់អត់ធ្វើអ៊ុចឹងទេតលូវហ្ន៎!!គាត់ល្អ!!កះច៉ា!!ខះបានគាត់នៅវត្តនៅអីអ៊ុចឹង!! គាត់ដឹងខុសត្រូវកាលហ្នឹង!!

កះច៉ា!!តែនៅវត្តគឺច្រើនតែប្រាសចាកពីអីដែលអាក្រក់ៗហើយពូណោះ??

ខះពីអាក្រក់ៗហ្នឹងហើយ!!

កះគាតកាន់សីលកាន់អីប៉ុន្មានទៅពូ??

ខះគាត់កាន់សីលកាន់អីគាត់ ដឹងសីលប៉ុន្មានទេ
អត់ដឹងដែរទេនេះ!!គ្រាន់តែដឹងថាគាត់នៅវត្តគាត់ចាក់មេក្រូចាក់អីនៅហ្នឹងវត្តហ្នឹង!!

កះច៉ាហ្នឹងហើយ
អ៊ុចឹងលោកពូអ៊ុចឹងពីដើមមកតើឪពុករបស់លោកពូដូចជាពីដើមមកដូចជាគាត់ប្រកបមុខរបរអីគេដែរដើម្បីចិញ្ចឹមកូនចៅមកអ៊ុចឹងហ៊ា??

ខះបាទ គាត់ពីដំបូងឡើយគាត់ដូចជាញ៉ុមអញ្ចឹងដែរកាលជំនាន់រដ្ឋកម្ពុជា
គាត់រត់កង់ឌុបកាលហ្នឹងជំនាន់កង់ឌុបនោះ!!កះច៉ា!!ខះរត់នៅតាខ្មៅយកមកតាខ្មៅយើងឈៀងក្រោមទៅ
ហើយគាត់ទៅរត់នៅភ្នំពេញអីអ៊ុចឹងទៅ!!កះហ៊ីៗ!ខះជំនាន់ជិះកង់អត់មានម៉ូតូអត់មានអីទេ!! ជំនាន់ហ្នឹងជំនាន់កង់ឌុប។

កះអត់មានម៉ូតូអីមួយៗទេហី??

ខះហ្នឹងហើយចិញ្ចឹមកូនចៅហា!អ៊ុចឹងមានអី ហ្នឹងមុខរបរគាត់។

កះហ្នឹងហើយ។

ខះហើយបន្ទាប់មកគាត់ដាក់មងរកត្រីរកអីដូចខ្លុំអ៊ុចឹង!!អ៊ុចឹងអីដែរហ្នឹងទៅ!!ចេះតែរកអ៊ុចឹងទៅ។

កះពូ គាត់មានធ្លាប់ធ្វើស្រែធ្វើអី?

ខះធ្លាប់ធ្វើ មានស្រែមានអីធ្វើដែរ!!

កះច៉ា!!ហើយពូជួយធ្វើគាត់អ៊ុចឹងទៅ??

ខ:បាទ!!ឥឡូវដីហ្នឹងវាអស់ហើយ លក់អស់រលីងហើយជំនាន់ហ្នឹង!!

ក:ហ្ន៎លក់តាំងពីយូរណាស់ហើយហេ??

ខ:លក់យូរហើយតាំងពីដីថោកៗណោះ!!

ក:បើទុកឥឡូវមិនបាច់ទេពូណោះ??

ខ:បើទុកឥលូវគេធ្វើស្អីឡើងពេញហ្នឹងអស់ហើយ
ដីយើងហ្នឹង!!ក:ហ្អូ!!ខ:មើលមកកន្លែងយើងខាងក្រោយនេះសុទ្ធតែដីស្រែដីអីហ្នឹង។

ក:ចំ!!ឥឡូវអ្នកណាគេមានដីមានអីអ្នកហ្នឹងមានម៉ងពូ!!ខ:បាទហ្នឹង!!ក:ញ៉ែមឮបងញ៉ែមនិយាយហាពូថាអ្នកច្រូតស្មៅទេណាស់!ប៉ុន្តែមានដី២ហិចតា!!ខ:បាទ!!ក:ហើយដល់ពេលអាចំលងអាផ្លូវ៦០ម៉ែត្រនៅព្រែកហូរហ្ន៎ពូ!!

ខ:ហ្នឹងនៅព្រែកហូរ!!

ក:គេអោយ២លានដុល្លារ ឥលូវគឺថាឈប់ធ្វើអីតែម្តង
ចុះមានលុយ២លានដុល្លារនៅហ្នឹងដៃហើយហ្នឹង!!ខ:បាទ!!
ក:សំណាងម៉ងហាអ្នកច្រូតស្មៅអោយគេសោះហ្នឹងហ៎!!ខ:ហ្នឹង!!ក:ប៉ុន្តែមានដី២ហិចតាគឺថាដីហ្នឹងដីព្រៃដីអីទេ!!ខ:បាទ!!ក:ដល់ពេលហើយវាចំដំដែលគេអភិវឌ្ឍន៍ខ្លាំងហ្ន៎ពូ!!ខ:បាទ!!ក:នៅជាប់ជាយក្រុងហ្នឹងហ្ន៎!!ចុះកន្លែងហ្នឹងពេលមុនសុទ្ធតែបឹងសុទ្ធតែអីហ្នឹង
អ្នកណាគេទៅគិតដល់ថាអ្នកណាគេធ្វើផ្លូវកាត់មកដល់ហ្នឹង។

ខ:មិននឹកស្មានថាផ្លូវកាត់ហ្នឹង!!

ក:ហ៊ីដល់ពេលឥលូវវិញ!!ពូលុយ២លានដុល្លារមិនមែនតិចទេណាស់!!!

ខ:ច្រើនតើ!!

ក:ចាយមួយជីវិតហ្នឹងមិនចង់អស់!!

(ប្រពន្ធលោកពូ):ចាយអត់អស់ទេលុយហ្នឹង!!

ក:ហ្នឹងហើយ!!ចំ!!

ខ:កុំតែយកទៅបំផ្លាញ។

ក:ហ្នឹងហើយ បើសិនជាលេងល្បែងលេងអីចប់ម៉ង!!

ខ:ចប់ហើយ!!

ក:ចំអ៊ុចឹងលោកពូមានអីចង់និយាយបន្ថែមទៀតពីឪពុករបស់ពូគាត់ម៉េចដែរ
ចិញ្ចឹមកូនចិញ្ចឹមអីអ៊ុចឹងហ៎??

ខ:មានអី!!

កៈគាត់ប្រដៅ ការប្រដៅគាត់ប្រដៅម៉េចដែរទៅកូនទាំងអស់?

ខៈគាត់ណែនាំអៅយកូនល្អទាំងអស់។

កៈចំ៎ ចំ៎!!អ៊ុចឹងឥឡូវគឺគាត់អត់មាននៅជាមួយកូនណាហិ គឺនៅវត្តហ្នឹងម៉ង?

ខៈនៅវត្ត។

កៈហ្នឹងហើយ អ៊ុចឹងលោកពូចូលដល់ម្តាយរបស់លោកពូវិញម្តងគាត់ឈ្មោះអីគេដែរ?

ខៈម៉ន ថុល។

កៈគាត់នៅរស់?

ខៈគាត់នៅរស់។

កៈអ៊ីចឹងគាត់អត់មាននៅវត្តជាមួយប្តីគាត់ណាហិ??

ខៈអត់ផងគាត់នៅផ្ទះ!!កៈចំ៎!!ខៈហើយគាត់មកផ្ទះម្តងម្កាល។កៈចំ៎!!ខៈយប់ម៉ោង៤ម៉ោង៥ទៅវត្តអីអ៊ីចឹងទៅ។

កៈចំ៎អ៊ីចឹងសំរាប់ឆ្នាំខ្ចែរសំរាប់ម្តាយរបស់លោកពូគាត់កើតឆ្នាំសត្វអីគេវិញ?

ខៈឆ្នាំជូត!!ជូតដែរ កណ្តរដូចញ៉ូមដែរដូចគេហៅថាពងឃ្មុទេវតាអ៊ីចឹងហ៎!!ហ្នឹងហើយ!!

កៈចំ៎អ៊ីចឹងអើរសំរាប់ថ្ងៃខែឆ្នាំកំណើតរបស់ប៉ាហាម្តាយរបស់លោកពូកើតឆ្នាំ
កើតថ្ងៃខែឆ្នាំណាពូអាចមើលនៅក្តងសៀវភៅកំណើតរបស់ពូហ៎ាវាមានបញ្ជាក់។

ខៈនៅកន្លែងណា??

កៈនេះនៅខាងនេះ ខាងនេះ!!

ខៈម្តាយ!!

កៈនេះៗៗថ្ងៃទី១២។

ខៈ១២ខែសីហាឆ្នាំ១៩៤៧!!

កៈចំ៎អ៊ុចឹងម្តាយរបស់លោកពូបងរបស់ប៉ាវិញ?

ខៈបាទបង!!

កៈបងៗឆ្នាំ??

ខៈហ្នឹងហើយ។

កៈចំ៎អ៊ុចឹងទីកន្លែងកំណើតរបស់គាត់នៅណាវិញពូ??អាចប្រាប់នៅណា?

ខ:គាត់កើតនៅ!!

ក:ភូមិព្រែកខ្សែរ។

ខ:ព្រែកខ្សែរហ្នឹងហើយ ។ក:ចំ!!ខ:កំណើតគាត់!!

(ប្រពន្ធលោកពូ):ឃុំតែមួយរកាខ្ពស់តែមួយ។

ក:ចំ!!អ៊ីចឹងនៅភូមិព្រែកខ្សែរ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល។

ខ:ខេត្តកណ្តាល។

ក:ចំាអ៊ីចឹងម្តាយក៏នៅរស់ដែរ
សព្វថ្ងៃហ្នឹងគាត់បងរបស់ចំាពូពាន្នាំ។ខ:បាទ!!ក:អ៊ីចឹងពូសំរាប់ម្តាយរបស់លោកពូ
តើពុចាំអីគេខ្លះពីម្តាយរបស់ពូដែរធ្លាប់រស់នៅជាមួយគាត់អ៊ីចឹងហ៊ា??

ខ:បាទ!!ចំា!

ក:ចាំអីគេខ្លះពីគាត់ គាត់ចរិកម៉េចដែរម៉ែ??

ខ:គាត់រៀងអត់ការអត់ធ្មត់បន្តិចគាត់រៀងកាច។

ក:ម៉េចខ្លះពូរៀបរាប់ពេលគាត់វែម្តងៗម៉េចដែរ??ម៉េចទៅពូ?

ខ:គាត់និយាយអីច្រើនតែត្រចៀកសរតាមគេហ៊ា!!

ក:ចំាជឿគេច្រើនអ៊ីចឹងហេ??

ខ:ជឿគច្រើនហើយញុងញ៉ាំងដាក់កូនថៅអ៊ុចឹងទៅហើយគាត់អត់មានការអត់ធ្មត់ហើយយើង
ប្រាប់គាត់ទៅគាត់នៅតែអ៊ីចឹង។

ក:ដល់ពេលកូនប្រាប់ហើយ ឥឡូវដល់ពេលកូនប្រាប់ម៉ែវិញហើយឥឡូវហ្នឹ
ដល់ពេលអ៊ុចឹងគាត់ញូវញ៉ាំងពេកហេ??

ខ:ញូវញ៉ាំងហ្នឹងហើយ។

ក:នាប់ខឹងម៉ងហេម្តាយ?

ខ:នាប់ខឹងហ្នឹងហើយ។

ក:គេប្រាប់អីជឿអ៊ុចឹងទៅ??

ខ:ហ្នឹងហើយ។

ក:ហើយអ៊ីចឹងបើសិនជាពេលប្រាប់ទាំងអស់ហើយ ហើយដឹងការពិតហើយនៅតែខឹងទៀតទៅ??

ខ:គាត់តែអ៊ុចឹង។

កៈចំាអ៊ុចឹងសំរាប់តលូវសព្វថ្ងៃគាត់ធ្វើអីគេដែរ?

ខៈធ្វើនំធ្វើអីលក់រាល់ថ្ងៃ។កៈចំា!!ខៈតែរាល់ដងគេកម្ម៉ង់អីអ៊ុចឹងទៅ គាត់ធ្វើអន្សម ធ្វើអីទៅធ្វើអោយគេគេកម្ម៉ង់ គេការ គេធ្វើបុណ្យអីអ៊ុចឹងទៅគាត់បាន។

កៈចំា!!ហ្នឹងហើយអ៊ុចឹងគាត់តលូវម្ដុំផ្ទះជិតពូ?

ខៈនេះផ្ទះគាត់នេះ។

កៈនេះជាប់នេះតែម្ដងហេ??

ខៈហ្នឹងហើយ។

កៈញ៉ូមស្មានតែឆ្ងាយ!!អ៊ុចឹងសំរាប់ពេលពូនៅពីក្មេងតើគាត់ប្រកបមុខរបរអីចិញ្ចឹមពូដែរ?

ខៈគាត់ខំខ្ចាស់ខ្មែងជាងឪទៀតគាត់!!

កៈម៉េចទៅ

ខៈគាត់ចាក់លៀសចាក់អីរកត្រីគាត់ដូចមនុស្សប្រុសអ៊ុចឹង!!ហ្នឹងហើយ គាត់ធ្វើអីដូចមនុស្សប្រុសអ៊ុចឹង។កៈចំា!!ខៈគាត់រាយសន្ដូច គាត់អត់រើសអើងទេ!!រាយសន្ដូចរកត្រីដូចគេធម្មតា គាត់មនុស្សស្រី តែធ្វើការដូចប្រុស!!

កៈអ៊ុទូក!!

ខៈហ្នឹងហើយអ៊ុទូក ចាក់លៀសចាក់អី តិចថាមនុស្សប្រុសចាក់លៀសទាន់គាត់ចុះ!!គាត់អត់ទេ!!

កៈចាក់លៀសហ្នឹងម៉េចទៅពូ?

ខៈចាក់លៀស អូសលៀសនៅលើទូកហ៎ា នេះបឹងស្ទឹងយើងហ្នឹង គាត់ចាក់បានកាលហ្នឹងជំនាន់ហ្នឹងលៀសច្រើនតលូវរាអស់ហើយហើយ!!កៈចំា!!ខៈគាត់ចាក់បានមួយថ្ងៃ៤ ៥ធុងអីហ្ន៎!!ហើយអ្នកអត់ចេះចាក់អីមួយតៅអត់ឈ្នះគាត់ទេ!!

កៈអត់យល់ ចាក់ម៉េចទៅអត់យល់ម៉េចទៅពូ?

ខៈញ៉ូមអត់យល់ដែរ គេមានឈ្មៀងអីគេ អូសអីវ៉ាន់ហ្ន៎!!

កៈអួសហ៎!!

ខៈអូសហ្នឹងហើយ។ហើយ៤ជ្រុង គាត់ប្រសប់អូសចូលមក បើអ្នកអត់ប្រសប់អូស អូសចូលតែខ្មែលលៀសចេញអស់ហើយ គាត់ចេះដឹងជំរៅម៉េចអីម៉េចគាត់ប្រសប់ម៉ងហ៎!!

កៈហ្ន៎អ៊ុចឹងជំនាញម៉ងហើយហេ??

ខៈបាទ!!

កៈចុះពីក្មេងមកប្រដៅពូអីវ៉ាន់ម៉េចដែរនៅពីក្មេង?

ខ៖គាត់ណែនាំអោយកូនល្អ ហើយកុំធ្វើអីអត់ល្អហ្នឹងហើយ!!!

ក៖ពេលខ្លះម្តាយឪពុកក៏ស្រលាញ់កូនរៀងច្រលាសដែរមើលទៅស្រលាញ់កូនស្មើគ្នាឬក៏ស្រលាញ់ប្អូនជាងគេអ៊ុចឹង??

ខ៖ដូចជាស្រលាញ់ប្អូនៗខាងណោះជាង ញ៉ាមបងគេដូចអត់សូវយកចិត្តទុកដាក់។

ក៖ស្រលាញ់កូនពៅហ៎??ស្រលាញ់កូនពៅជាងពូហេ??

ខ៖ស្រលាញ់។

ក៖តែរាល់ថ្ងៃគាត់នៅជាមួយកូនពៅឬក៏កូនទីប៉ុន្មាន?

ខ៖នៅជាមួយពៅ។

ក៖ហ្នឹងហើយ អ៊ុចឹងម្តាយរបស់ពូខ្លាំងណាស់!!ជាងប្រុសទៀតហេ??

ខ៖ជាងប្រុស។

ក៖រាល់ថ្ងៃគាត់នៅតែមានកំលាំងពេញអ៊ុចឹងហេពូហ៎?

ខ៖បាទនៅតែមានកំលាំងអ៊ុចឹង ខ្លាំង អ្នកណាផ្តល់សរសៃរផ្តង់អីវ៉ាន់ហ៊ា ចាប់សរសៃអីវ៉ាន់ដៃគាត់ទូចៗទេតែថាចាប់មួយខឹសៗអីឡើងចង់ហៀរទឹកភ្នែក ក្រិចឆ្អឹងដៃគាត់ដូចរឹងម៉ងហ៊ា!!ក៖ចំ!!ខ៖គាត់ចាប់សរសៃអីអោយគេអ្នកណាផ្តល់សរសៃអីវ៉ាន់គាត់ចាប់បាត់!!

ក៖ហ្ន៎!!គាត់មិនមែនគ្រូអីណាហី??

ខ៖គាត់គ្រូចាប់សរសៃអត់ទេ នេះគាត់ស្មងពិយាយញ៉ាមយាយញ៉ាមគាត់អ្នកចាប់សរសៃរដែរយាយកិននោះ។ក៖ចំ!!ខ៖ហ្នឹងហើយ ម៉ែម៉ែគាត់ហ្នឹង។

ក៖គាត់ដឹងរបៀបត្រូវចាប់មែនពូបានអ៊ុចឹង?

ខ៖បាទហ្នឹងហើយ គាត់ស្ទាប់អីម៉េចអីម៉េចទេ គាត់ថាហ្អនេះកន្លែងនេះកន្លែងនេះម៉េចអីម៉េចគាត់ស្តីៗទៅបាត់ទៅ អ្នកចាប់សរសៃមួយកំនមករកគាត់។ក៖ហ្ន៎!!ខ៖ហ្នឹងហើយ។

ក៖ហើយចុះគាត់អត់មានស្មងមួយហ្នឹងអោយអ្នកណាគេទេហេ??

ខ៖ស្មងអោយ ដឹងអីញ៉ាមអត់ដឹងដែរបែបមានតែគាត់ហ្នឹងម្នាក់ទេមិនស្មងអោយអ្នកណាគេទៀតហ្ន៎!!

ខ៖ពូសាកវៀនពីគាត់ទៅ ?

ខ៖អត់ចេះ។

ក៖គាត់តែសាកនេះ ស្នាមស្នាមដឹង។

(ប្អូនថ្លៃលោកពូ)៖ធ្លាក់ទៅដល់ប្តីញ៉ុមហើយ។

ខ៖អាជូន។កះហ្គំ!!

(ប្អូនថ្លៃលោកពូ)៖ញ៉ុមទៅថៃទៅអីគេថ្លស់ចង្កេះថ្លស់អីគាត់
គាត់ប្រាប់នេះហ្នឹងហ៊ា!!ប្រាប់អាពន្លឺចាប់សរសៃហ្នឹងហ៊ា!!កះចំ!!ខះហើយដល់ពេលនេះប្តីញ៉ុមចាប់អោយគេបាត់។

កះចំ!!ហ្គំអ៊ុចឹងឥឡូវផ្ទេរទៅអោយពូជូនវិញ?

(ប្អូនថ្លៃលោកពូ)៖ហ្នឹង។

កះពូជូនអ្នកជំនាញចាប់សរសៃដែរហើយឥលូវ។

(ប្អូនថ្លៃលោកពូ)៖ជំនាញចាប់សរសៃរ។

កះអ៊ុចឹងអត់អីទេ បាននេះដែរតើ!!បានតអោយកូន!!ទីប៉ុន្មានពូជូន??ទី២ហេ??

ខ៖ទី២ បន្ទាប់ពីញ៉ុម។

កះពូចំនុចកន្លែងមួយណាដែលស្រលាញ់ម៉ែជាងគេ?មានចំនុចណាក្រៅពីកន្លែងគាត់ឆេរឆាវហ្នឹងអីវ៉ាន់ មានកន្លែងណាស្រលាញ់ជាងគេអីអត់?

ខ៖នៅតែស្រលាញ់គាត់ហ្នឹងប៉ុន្តែគាត់នៅឆេរឆាវម៉េចក៏ដោយ។

កះចំាតែចំនុចពិសេសជាងគេហ៊ាដែលគាត់មើលទៅល្អបំផុតក្នុងតែវភ្នែករបស់ពូហា!មួយណាទៅពូមានមួយហ្នឹងអត់?ថាម៉ែញ៉ុមល្អចំនុចមួយនេះដែលល្អបំផុតដែលញ៉ុមស្រលាញ់ជាងគេហិ??

ខ៖អត់យល់!!

កះដូចថាចំនុចដែលគាត់ល្អជាងគេបំផុតម៉ងហាពូហ៊ា??ខះបាទ!!កះគិតថាចំនុចមួយណា??

ខ៖មិនដឹងរកនឹកម៉េច??ចំនុចកន្លែងម៉េច?

កះចំនុចគឺថាគឺគាត់ល្អខ្លាំងជាងគេបំផុតម៉ង ម៉ែតែនេះមនុស្សម្នាក់ៗហ៊ាសុទ្ធតែមានចំនុចល្អចំនុចអាក្រក់មែនទេពូ?

ខ៖អាហ្នឹងដល់តែយើងបញ្ចោរគាត់តិចអីតិចអ៊ុចឹងទៅគាត់ដោរតាមយើង។

(ប្អូនថ្លៃរបស់លោកពូ)៖គាត់ដូចថាគាត់ចង់
ដូចថាគាត់ធ្វើអីមួយហើយគាត់ត្រូវចែកកូន។កះហ្គំ!!ខះហ្នឹងហើយ។

កះអ៊ុចឹងគាត់ចែកកូនស្មើពូហេ??

ខ៖គាត់ចែកតើ
គាត់ចែកអីចែកសំលរហៅកូនចៅហៅចែកមួយនាក់មួយចានមួយនាក់មួយចានមានអីស្ងាញ់អីអ៊ុចឹងហ៊ា ទោះខឹងប៉ុន្មានក៏នៅតែអោយ!!កះហ្គំ!!ខះអ៊ុចឹងចំនុចមួយហ្នឹងហើយល្អហ្គំពូ!!ខះបាទ!!

កះចុះមានដែលចុះតលូវអញ្ចេក
ម៉ែឪមិនដែលមានចែកទ្រព្យសម្បត្តិអីអោយពូទេ??អោយពូកូនចៅគ្រប់ៗគ្នាមានចែកអីអោយអត់??

ខះដូចអត់ផងៗ

(ប្រពន្ធរបស់លោកពូ)៖អត់ចែកម៉េចកើរ៉ីអាការដីគាត់ហ្នឹង!!!

ខះអើរដីនេះ ម្នាក់ដុំដែរ មិនមែនចែកជាលុយទេ!!កះចាំ!!ខះចែកជាដីហ្នឹងៗ

កះដូចម៉ែញ៉ាមដែរ ចែកអោយពួកញ៉ាមគ្រប់គ្នាហើយអស់ហើយ

ខះបាទ!!ធ្វើប្លង់ធ្វើអីហើយអស់ហើយ។កះចាំ!!

(ប្អូនថ្លៃរបស់លោកពូ)៖ចេញប្លង់រឹងហើយអស់រៀងៗខ្លួនហើយហ្នឹង!!

កះហ្នឹងហើយហ៊ីអ៊ុចឹង
អើរបានមួយហ្នឹងចំនុចល្អ!!ខះបាទ!!កះគិតទៅចាស់ៗជំនាន់មុនសុទ្ធតែមានដីអីអ៊ុចឹងចែកកូនចៅអ៊ុចឹងហ៊ាពូ។ខះបាទ!!កះចុះដល់ពេលយើងជំនាន់តឡូវ??

ខះដល់ជំនាន់តឡូវអស់ហើយ

(ប្អូនថ្លៃរបស់លោកពូ)៖ស្រែករញ៉ាមក្រោយចប់អត់មានដីចែកកូនទេ!!

ខះអោយវានៅផ្ទះឋ អោយនៅផ្ទះជួល!!

កះតឡូវបើនៅសុទ្ធតែនៅផ្ទះមួយប្លង់ៗ!!ខះបាទ!!កះផ្ទះល្វែងផ្ទះអី

(ប្អូនថ្លៃលោកពូ)៖អញ្ចេកដូចពេលអនាគតទៅដូចដីបងញ៉ាមអ៊ុចឹង ចែកកូនមួយប្លង់ៗធ្វើផ្ទះ!!

កះជាប់ៗគ្នា

ខះជាប់ៗគ្នា

កះអ៊ុចឹងរកផ្លូវរៀងៗខ្លួនដោយខ្លួនឯង អត់ដឹងទេ
គាត់អត់ទទួលខុសត្រូវទេ!!បានតែត្រឹមផ្តល់កំនើតអោយចិញ្ចឹមតាំងពីទូចដល់ធំទេ!!

ខះហ្នឹងហើយ

កះអ៊ុចឹងតឡូវគេបន្តិចទៀត
សំរាប់ចូលដល់ជីដូនជីតាពូវិញម្តងសំរាប់ខាងតឡូវសួរខាងម្តាយវិញថាលោកតារបស់លោកពូគាត់ឈ្មោះអីគេដែរ?

ខះខាងម្តាយញ៉ាម?កះចាំ!!ខះប៉ុនម៉ែញ៉ាមដាក់ឪពុកស៊ីមទេ ប៉ុន្តែគាត់យកត្រកូលម៉ន!!ម៉នយក

កះចាំម៉ន ស៊ីម

(ប្រពន្ធរបស់លោកពូ)៖ អាហ្នឹងគាត់យកជីតាទេ បើឪពុកគាត់ឈ្មោះស៊ីម។

ខ៖ហ្នឹងហើយ។

(ប្រពន្ធលោកពូ)៖គាត់យកត្រកូលជីតាប្រើហ៊ា!!គាត់អត់យកត្រកូលឪពុក។

ខ៖ហ្នឹងហើយ ហ្នឹងហើយ ម៉ន ស៊ីម ហ្នឹងហើយៗ!!!

ក៖ចា!!ហើយលោកពូកើតទាន់គាត់ទេតា??

ខ៖អត់ទាន់ផង!!ហេទាន់តាស៊ីមទាន់ គាត់ស្លាប់ហើយ។

ក៖គាត់ស្លាប់ហើយពេលឆ្នាំណាវិញពូ?

ខ៖ជំនាន់ ជំនាន់គេវ៉ៃគ្នាហ្នឹង។

ក៖គេវ៉ៃគ្នាបែក!

ខ៖គេវ៉ៃគ្នាបែកប៉ុល ពត ៧៩(១៩៧៩)។

ក៖ហ្ន៎អ៊ីចឹងជំនាន់ពេលសង្គ្រាមហ្នឹងគាត់អ្នកនេះ!!

ខ៖ហ្នឹងហើយគាត់ស្លាប់នៅព្រៃកខ្សែរហ្នឹងដែរ!!ក៖ហ្ន៎!!ខ៖ហ្នឹងហើយ ស្លាប់នៅក្នុងជំនាន់ប៉ុលពតហ្នឹង??

ខ៖ស្លាប់នៅក្នុងជំនាន់ប៉ុល
ពតហ្នឹងគាត់ស្លាប់ជំងឺគាត់ឈឺហ្នឹងមិនមែនគាត់ស្លាប់ដោយសារគេវ៉ៃចោលទេ!!

ក៖ហ្ន៎ជំងឺស្អីគេវិញពូជំងឺពេលហ្នឹង?

ខ៖អត់ដឹងជំងឺស្អីគេទេគាត់ ស្លាប់ទៅ?

ក៖ស្លាប់ទៅហេ??ខ៖បាទ!!ក៖អ៊ុចឹងពូចាំអីគេខ្លះពីតាដែរអីវ៉ាន់អ៊ីចឹងតើគាត់ម៉េចដែរទៅ?

ខ៖តាហ្នឹងគាត់កាចដែរ ជំនាន់ហ្នឹង!!

ក៖ម៉េចវិញទៅពូ?

ខ៖គាត់កាច។

ក៖គាត់កាចរបៀបម៉េចដែរគាត់កាចខូចឬក៏កាចត្រូវ?

ខ៖កាចត្រូវណែនាំកូនអោយល្អ។

ក៖ណែនាំអីអ៊ីចឹងទៅប្រៀបប្រដៅអីអ៊ីចឹងទៅពូណោះ??

ខ៖បាទណែនាំអោយកូនចៅគាត់ហ្នឹង។

កៈថា ពូចាំថាតាគាត់កើតជំនាន់ណាអត់?ឬក៏ឆ្នាំណាពូស្គាល់ទេ??

ខៈអត់បានដឹងដែរម៉ែញ៉ុម អត់បានដឹងដែរ!!

កៈថា!!តែពេលគាត់ស្លាប់ហ្នឹងស្លាប់អាយុប៉ុន្មានទៅពូ??ដឹងទេ??

ខៈអាយុប៉ុន្មានទេនេះអត់ប្រាប់ អត់ប្រាប់សួរម៉ែម៉ែអត់ដឹងអាយុប៉ុន្មានដែរនេះ??គាត់ប្រហែលជាអាយុគាត់ហ្នឹង ស្លាប់ប្រហែលជា៥០ជាង ។

កៈ៥០ជាងទេហេ??

ខៈបាទ!!

កៈក្មេងដែរហ្នឹងអ៊ីចឹ??

ខៈក្មេង!!

កៈថាអ៊ីចឹងពូចាំថាស្រុកកំណើតរបស់តាគាត់អ្នកនៅណារឿញ?ស្រុកភូមិណាដែរ??

ខៈគាត់ គាត់នៅដូចនៅអើរតានៅណាទេនេះ??

កៈអ្នកស្រុកជាមួយយាយដែរឬក៏មកពីណាឆ្ងាយមកនៅហ្នឹង??

ខៈគាត់ដូចកាលដំបូងថានៅពោធិ៍សាត់អ្នកស្រុកគាត់។កៈហ្ន៎!!ខៈពោធិ៍សាត់ហើយមកសព្វថ្ងៃយាយញ៉ុមហ្នឹងនៅទន្លេឯណេះ។

កៈហ្ន៎នៅស្អាងនេះទេ!!ខៈបាទ!!

ខៈហើយជំនាន់ហ្នឹងឮសូរយាយៗឮសូរថាសុទ្ធតែជិះដំរីជិះអីមកស្តីដណ្តឹងហ៊ា??កៈចំ!!ខៈកាលហ្នឹងជំនាន់ចាស់ៗ មានដំរីមានសេះមានអី។

កៈអូយ!!ឡយណាស់អ៊ីចឹង!!

ខៈជំនាន់ចាស់បុរាណ។

កៈថា ជំនាន់ហ្នឹងប្រហែលសំបូរដំរីច្រើនហើយពូណោះ??

ខៈបាទហ្នឹងហើយ ។

កៈតែឥឡូវមានប៉ុន្មានទេអស់រលីងហើយ!!អស់ព្រៃអស់អីហើយ!!ខៈបាទ!!កៈគេចាប់ទៅស្រុកគេឬក៏វាងាប់វាអីអ៊ុចឹងទៅពូណោះ??

ខៈហ្នឹងហើយ។

កៈហ្នឹងហើយពេលមុនភាគច្រើននៅប្រទេសយើងពេលសង្គ្រាមអីវ៉ាន់គេយកដំរីទៅច្បាំងអីវ៉ាន់។ខៈបាទ!!កៈប៉ុន្តែឥឡូវដំរីអីវ៉ាន់នៅអង្គរវត្តមានតែប៉ុន្មានហ្នឹង!!

ខៈមានប៉ុន្មានហ្នឹងមិនដឹងទៅណាអស់ បែបមានប៉ុន្មាន មិនដឹងយកទៅដាក់ណា!!

កៈចំាអានិតគ្នា!!

ខៈនៅភ្នំតាម៉ៅដូចអត់មានអត់សូវមានទេ!!

កៈមានតែប៉ុន្មានហ្នឹង!!

ខៈហ្នឹងហើយ។

កៈញ៉ែមទៅថ្ងៃមុនឃើញមានតែបន្តិចមួយហ្នឹង។ខៈបាទ!!កៈសត្វហ្នឹងគួរអោយអានិតណាស់មុខ។

ខៈហ្នឹងហើយ។

កៈមាខជំមែនតែធ្វើភ្លើៗ។

ខៈហ្នឹងហើយ ភ្លើៗមែន!!

កៈចំាលោកពូមានអីចាំពីតាទៀតទេ??

ខៈអត់ចាំទេ!!

កៈចំាឥឡូវចូលយាយវិញម្តងយាយខាងម្តាយហ្នឹងគាត់ឈ្មោះអីគេវិញ??

ខៈឈ្មោះយាយហេង។

កៈត្រកូលគាត់ហាពូថែមទៀត??

ខៈហេង កិន។

កៈហេង កិន??ខៈបាទ!កៈហ៎ាម៉េចយាយហេងវិញ?នេះហាត្រកូលហាយាយឈ្មោះអីគេ??ហើយត្រកូលគាត់អីគេដែរ??

ខៈត្រកូល!!ឈ្មោះហេងហ្នឹងហើយ!!

កៈហេង កិន?ខៈបាទ!!កៈយាយ យាយឈ្មោះ យាយកិន?

ខៈយាយកិន!!កៈចំា!!ខៈឪពុកគាត់ឈ្មោះហេង។

កៈចំា!អ៊ុចឹងផ្សេងពីគ្នាអ៊ុចឹង!!

ខៈផ្សេងពីគ្នាមិញនិាយយជីតា។

កៈចំា!!ហ្នឹងហើយ!!

ខៈម៉ន ស៊ីមហ្នឹង។កៈចំា!!ខៈឥឡូវមកយាយវិញ!!

កៈយាយវិញម្តង យាយឈ្មោះយាយកិន។

ខៈយាយកិនហ្នឹងហើយ។

កះពូកើតទាន់គាត់ទេ??ខះបាទ??កះកើតទាន់យាយអត់?

ខះអត់យាយហ្នឹង អត់ទាន់ផងង!!

កះគាត់ស្លាប់មុនពេលពូកើតទៀតហេ??

ខះបាទ!!ហ្នឹងហើយ ស្លាប់មុនកើតទៀត!!

កះហ្ន៎!!ហើយមានដែលម៉ែប្រាប់ថាយាយម៉េចៗទេ??

ខះអ់តដែលប្រាប់ទេ គ្រាន់តែឈ្មោះ ប្រាប់តែឈ្មោះថាឈ្មោះយាយហេងអ៊ីចឹងទៅ!!

កះចំ៎!!ក្រកូលហេង។

ខះហាក្រកូលហេង!!

កះយាយកិន។

ខះហ្នឹងហើយ។

កះអត់មានកាចក្រចៀកសរដូចយាយអីទេហី?

ខះអត់ទេ!!

កះហ្នឹងហើយ!!អ៊ីចឹងមិញពូដឹងថាគាត់កើតជំនាន់ណាអីទេហី??

ខះអត់ស្គាល់ផងង!!

កះតែគ្រាន់តែដឹងថាតាមកចូលស្តីដណ្តឹងយាយហ្នឹងជិះដំរីជិះសេះមកពីពោធិ៍សាត់?

ខះហ្នឹងហើយ
ហ្នឹងហើយឮយាយៗគាត់និយាយប្រាប់។កះចំ៎!!ខះយាយញ៉ែមយាយកិនហ្នឹងគាត់និយាយប្រាប់។កះចំ៎!!ខះចៅៗហ្នឹងហ៎!!

កះតែពូកើតទាន់គាត់អត់អ៊ុចឹង??

ខះអត់ទាន់ទេគ្រាន់តែគាត់និយាយពីរឿងដែលថាតាមកចូលស្តីយាយហ្នឹងជិះសុទ្ធតែដំរីតែអីមក!!

កះហ្ន៎!!គ្រាន់តែប្រាប់ម្តាយរបស់ពូ ម្តាយរបស់ពូប្រាប់មកតវិញ?

ខះប្រាប់មកតគ្នាហ្នឹងហើយ!!

កះចំ៎!!

ខះអត់ទេយាយញ៉ែម គាត់នៅរស់កាលគាត់និយាយប្រាប់យើងដែរយាយកិនហ្នឹង!!

កះហ្ន៎តែពេលហ្នឹងពូកើតទាន់គាត់ហើយមែនទេ??

ខ:កើតទាន់គាត់។

ក:ហ្នឹងហើយមិនមែនអត់ទាន់ទេ!!ខ:បាទ!!ក:អ៊ីចឹងទាន់យាយហ្នឹងដែរ!!

ខ:ហ្នឹងហើយ!

ក:អ៊ីចឹងពេលឆ្នាំណាបានគាត់ស្លាប់ហើយពូ??

ខ:គាត់ទឹមស្លាប់យើងប៉ុន្មានឆ្នាំនេះហេ??មើល!!ចូល៥ ៦ឆ្នាំហើយ។

ក:ហ្គ៎អ៊ុចឹងយាយកិនទឹមស្លាប់ទេអ៊ីចឹង??

ខ:ទឹមស្លាប់ហ្នឹង!!ក:ហ្គ៎!!ខ:ស្លាប់ពេលស្លាប់ហ្នឹងគាត់៨០ជាងហើយ។

ក:ស្លាប់នៅផ្ទះនេះដែរពូហេ??

ខ:ហ្នឹងស្លាប់នៅហ្នឹង ធ្វើបុណ្យនៅហ្នឹង!!

ក:ហ្គ៎ ពូមានបានទទួលការថែទាំអីពូយាយច្រើនទេ??

ខ:បាទអត់ផង!!

ក:អត់ទេ ផ្សេងៗពីគ្នា។

ខ:អត់ទេកាលពីទូចៗយាយគាត់មើលថែញ៉ុមដែរកាលពីជំនាន់ហ្នឹង
ជួយមើលអីម៉ែញ៉ុមទៅណាទៅណីអ៊ុចឹងជួយមើលញ៉ុមពីទូចៗអីអ៊ុចឹងទៅណាស់!!ក:ហ្គ៎!!ខ:នៅស្ទើរ
អត់ដឹងអីអ៊ុចឹងទៅណាស់!!ក:ចា!!ខ:ហ្នឹងអ៊ុចឹង!!

ក:ហ្នឹងអ៊ុចឹងដែរ!!ហើយមានដឹងថាគាត់អ្នកនៅស្រុកណាពូមាននដឹងទេយាយហ៎??

ខ:យាយហ្នឹងអត់ អត់ដឹតថាគាត់អ្នកស្រុកណាទៀតហិ មិនដឹងដែរ។

ក:កើតនៅស្រុកហ្នឹងឬក៏ផ្សេងពីហ្នឹង??

ខ:មិនដឹងថាគាត់កើតនៅស្រុកណាអត់ដឹងដែរ
ក្រាន់តែដឹងថាគាត់មកនៅព្រៃកខ្សេវហ្នឹង!!ហេព្រៃស្វា ហ្នឹងហើយនឹកឃើញហើយ ព្រៃស្វា។

ក:ព្រៃស្វា។

ខ:នៅព្រៃស្វា។

ក:ព្រៃស្វាហ្នឹងនៅណាពូ?

ខ:ព្រៃស្វាហ្នឹងនៅពត់សរយើងនៅ!!

ក:ហ្គ៎ស្គាល់ហើយ ហ្នឹងហើយតាកែវ។

ខ:តាកែវ។

កះចូលតាកែវវិញហើយហ្នឹង!!

ខះចូលតាកែវ ចូលមកយើង ហ្នឹងហើយចូលខេត្តតាកែវហ្នឹង ហ្នឹងកន្លែងពត់សរហ្នឹងចូលមកជ្រៅចូលមកក្នុង។

កះក្លោងទ្វារវត្តពត់សរហ្នឹងចូលមកទៅ?

ខះហ្នឹងហើយ!!

កះហ្នឹងហើយ!!មានពត់សរមានព្រៃស្វាអី!!

ខះហ្នឹងហើយស្រុកកំណើតគាត់ គាត់ថាគាត់កើតជានៅព្រៃស្វាហ្នឹង។

កះចំាហើយបាននាំគ្នាមករស់នៅព្រៃកខ្សែរនេះវិញទៅ!!

ខះហ្នឹងហើយបាទ!!បាទ

កះហើយក៏មករស់នៅនេះវិញទៀត អ៊ុចឹងគាត់ដូរទីលំនៅមិនមែនតិចដែរហ្នឹង!!!

ខះច្រើនកន្លែង!!

កះ២ ពាកន្លែងដែរ!!

ខះ ចុះគាត់តាំងពីជំនាន់ចាស់បុរាណណោះ??

កះចំា!!ខះគាត់ដូរច្រើនកន្លែង ។សូម្បីតែម៉ែញ៉ំមហ្នឹងក៏ច្រើនកន្លែងដែរ!!ជំនាន់ប៉ុលពតលើកកញ្ជើរដើរនេះដើរនោះ
ដីទំនេរចេះតែនៅទៅជំនាន់ហ្នឹងដីថ្លៃដូចឥឡូវលើកដាក់បានឯណាអត់

កះឥឡូវរាប់ម៉ឺនរាប់ម៉ឺន!

ខះរាប់ម៉ឺន។

កះចំា!!អ៊ុចឹងពូសំរាប់ចូលដល់ជីដូនជីតាពូខាងឪពុកវិញម្តង
ម៉េចម្តាយហើយហើយណាស់ពូណោះ??ខះបាទ!!កះអ៊ុចឹងចូលដល់ខាងឪពុកវិញតារបស់ពូខាងឪពុកគាត់ឈ្មោះអីដែរ?

ខះតាហម។

កះត្រកូលគាត់??

ខះត្រកូលគាត់ ឪពុកញ៉ំមឬកីអី?

កះអើរត្រកូលរបស់តាហ្នឹងហ៊ា??គាត់ឈ្មោះតាហមហើយ
ហើយមនុស្សគាត់ច្រើនតែមានត្រកូលមែនទេពូ??ខះបាទ!!កះហ្នឹងហើយ គាត់ត្រកូលអីគេដែរអីគេហម?

ខ:ហម ភៀង។

ក:ហម ភៀង !!

ខ:ហ្នឹងហើយប្តីប្រពន្ធគាត់ហ្នឹងហ៎ា!!

ក:ចំ!!និយាយថាត្រកូលរបស់គាហ៎ា??

ខ:ត្រកូលរបស់គា??

ក:ត្រកូលរបស់គាហ្ន៎?? ពូឈ្មោះចិន ចយ ត្រកូលចិនរបស់ពូហើយ ប៉ុន្តែហ្នឹងហើយ!

ខ:ហ្ន៎!!ហម ចិន។

ក:ហម ចិន!

ខ:ហ្នឹងហើយ ត្រកូលរបស់ឪញ៉មហ្នឹងហិ?

ក:តាតា។។??

ខ:តាហ្នឹងហើយគាត់ឈ្មោះតាហមហ្នឹងហើយ។

ក:ចំ!ប៉ុន្តែត្រកូលរបស់តាហមហ្នឹងឈ្មោះអីគេ?

ខ:អូរអត់ស្គាល់ទេ អត់ស្គាល់ទេ ដាច់!!

ក:តែត្រឹមហ្នឹងទេហេ?

ខ:ហ្នឹងហើយ តាហ្នឹងបាត់អត់ដែលឃើញមុខផងហ្នឹង តាំងពីជំនាន់បែកហើយ ញ៉មអត់ដែលស្គាល់ឥតម៉េច គ្រាន់តែថាបែកហើយស្គាល់ឈ្មោះគាត់តាហម ឪពុក ឪឪពុកញ៉មហ្នឹងហ៎ា!!

ក:បាត់ឈឺងពេលជំនាន់ប៉ុលពត?

ខ:ហ្នឹងហើយពេលជំនាន់ប៉ុល ពត បាត់រហូត បែកពីយាយញ៉មទៅរហូតមិនដាគាត់ទៅរស់នៅឯណា!!

ក:អូយញ៉មដឹងមិនស្រួលគេសម្លាប់ចោលសម្លាប់អីហើយពូហិ??

ខ:ហ្នឹង!!

ក:គាត់អ្នកចេះដឹងអីអត់ពូ??មានដឹងទេ?

ខ:គាត់ គាត់មិនមែនអ្នកចេះដឹងអីទេ មិនដឹងបាត់ បាត់គាត់រហូតទល់យាយញ៉មចាស់ អត់ដឹងនៅណាហើយកូនគាត់ ប៉ុន្មានច្រើនគ្នាណាស់ ៥ ៦នាក់ ហ្ន៎ ៨ ៩នាក់ហ្ន៎!!ហើយរត់ហ្នទៅចោលកូនអត់ដឹងកូនទៅណា!!នៅតែយាយហ្នឹងគាត់ក្រាប់ក្រងទៅហ្នឹង ហើយរហូតទៅ។

កះហើយចុះពេលហ្នឹងមុនបែកប៉ុល ពត ពូកើតទាន់គាត់តើហ៊ីគាត់នៅរស់មែនទេ??បែកទឹមពេលនេះហើយហ្នឹង!!

ខះតាហ្នឹងហ៊ី??កះចំ!!ខះតាឮសូរតែឈ្មោះប៉ុន្តែគាត់ស្លាប់ពេលណាអត់ដឹងដែរហ្នឹង!!

កះតែគ្រាន់តែដឹងតែនៅក្នុងរបបសង្គ្រាមហ្នឹង។

ខះហ្នឹងហើយ។

កះចុះដល់ពេលអត់ទាន់ចូលសង្គ្រាមហ្នឹងពូឃើញមុខគាត់ទេធ្លាប់ឃើញទេ?

ខះអត់ដែលឃើញទេ។

កះហ្ន៎អត់ដែលហេ??

ខះឃើញតែយាយទេ!!

កះឃើញតែយាយ?

ខះបាទ!!

កះតែមានប្រាប់ទេ យាយមានដែលដំនើររឿងតាអីប្រាបអីអត់ពូ?

ខះយាយអត់ដែលប្រាប់អត់ដែលអីផង??កះហ៊ីៗ!!ខះបើយាយញ៉ែមយាយខាងម៉ែញ៉ែមប្រាប់បើយាយអត់ដែល។

កះចំាភាគច្រើនឪពុកអត់សូវដែលប្រាប់ច្រើនទេពូហេ??

ខះបាទ!!

កះចំាហើយគាត់មកពីស្រុកណាវិញពូ??

ខះគាត់តាហមហ្នឹង គាត់ថាមកពីគេហៅគាត់ចិនកំពតចិនកំពត មកពីកំពតខេត្តកំពត។

កះហ្នឹងហើយ ខាងខ្សែចិនដែរហេពូហេ?

ខះហ្នឹងហើយខាងខ្សែចិនដែរហ្នឹង។

កះហ្ន៎!!អ៊ុចឹងឪពុករបស់លោកពូគាត់កាត់ខ្សែចិនដែរបានដាក់ឈ្មោះចិន??

ខះចិន ហ្នឹងហើយគាត់ខ្សែចិន ប៉ុន្តែឪពុកដែលចិនហ្នឹងគាត់មកពីខេត្តកំពតហើយឈ្មោះគេដាក់ឈ្មោះចិនកំពត ចិនកំពត។

កះគេហៅដោយសារគាត់មកពីហ្នឹង?ខះបាទ!!កះអ៊ុចឹងដល់យាយវិញម្តងយាយលោកពូឈ្មោះអីគេដែរខាងឪពុក?

ខះខាងឪពុកខ្ញុំហ្នឹងហេ?កះចំ!!ខះឈ្មោះឈ្មោះយាយភៀជ ។

កះចំ!!ពូស្គាល់ត្រកូលគាត់ទេ?

ខះអត់ស្គាល់ ស្គាល់តែយាយ!!

កះដាក់ ដឹងតែយាយភៀងមួយទេហេ??ខះបា!!កះពូមានបានធ្វើពង្សប្រវត្តិអីច្រើនទេ?

ខះដាក់ឈ្មោះដាក់អីគាត់ដែរ??

កះចំាហ្នឹងហើយ ពូចាំឆ្នាំគាត់កើតអីអត់?

ខះអត់ចាំដែរ។

កះអត់ចាំគាតអត់មានប្រាប់អី !!ខះបាទ!!កះនៅក្នុងអីអត់មានអ្នកណាគេដឹងអីទេហី??

ខះអត់!!

កះសួរជំាអីវ៉ាន់ដឹងទេពូ??

ខះសួរគាត់ ប៉ុនមិនដឹងអ្នកក្រួយកទៅបាត់ហើយ។

កះភ្លេចហើយពូហ៎??

ខះភ្លេច។

កះចំាពូពេលហ្នឹងនៅទាន់យាយដែរតើហេ កើតមកឃើញមុខគាត់ទេ??

ខះឃើញយាយភៀងញ៉ំមស្គាល់។

កះចំា!!គាត់ម៉េចដែរពូ អាចនិយាយពីយាយភៀងហ្នឹងគាត់ម៉េចដែរ?

ខះគាត់ គាត់ពីដំបូងឡើយគាត់មានអី!!!អើរចិញ្ចឹមក្រុមគ្រួសារញ៉ំម កាលហ្នឹងបានល្អដែរ!!កះចំា!!ខះហ្នឹង!!គាត់នៅកំពង់ព្រីងយើងនៅសិត្សហ្នឹង !!កះហ្ន៎!!ខះសិត្ស!!

កះហ្នឹងចូលស្រុកស្អាងហើយណោះពូណោះ?

ខះកាលហ្នឹងនៅឃុំសិត្ស។

កះចំា!!ខះបាទ!!កះអ៊ីចឹងរបៀបថាគាត់ប្រកបរបររកស៊ីអីគេដែរលោកពូចំណាស់ចំណាស់គាត់ហ្នឹងពេលពូស្គាល់ឃើញមកគាត់នៅតែផ្ទះឬក៏ម៉េច?

ខះគាត់អើរធ្វើស្រែធ្វើចំការមក គាត់មានដីមានធ្លីធ្វើ។

កះគាត់មានដីនៅម្ដុំហ្នឹងពូហេ??

ខះបាទ!!បាទ!!

កះពូមានដែលមានបងប្អូនអីឆ្លងដីទៅត្រើយម្ខាងទេ?

ខ:អត់ដែលមានបងប្អូន។

ក:ចា!!ដល់ពេលពូ ត្រើយដល់ពេលខាងណោះគេហៅកោះការដល់ពេលខាងណោះគេហៅអីគេវិញទៅពូ?នឹងកោះដែរតើពូហិ ហិអី?

ខ:កោះដែរ!!

ក:តែមានទន្លេខាងណោះអីទេ?

ខ:ហេអត់កោះទេ
!ហ្នឹងហើយមានទន្លេវាបែកហ្នឹងគេហៅកោះហើយ។ក:ហ្ហ!!ខ:បាទ!!ក:អ៊ុចឹងមានទន្លេខាងណោះហើយមានទន្លេនៅខាងណោះទៀតហេ??

ខ:មានទន្លេមួយទៀតហ្នឹងហើយបាទ!!
ក:ចា៎អ៊ុចឹងពូសំរាប់យាយហ្នឹងពេលពូមកដឹងក្តីមកជាមួយគាត់ហ្នឹងដូចគាត់ម៉េចដែរគាត់មានដែលមើលថែទាំពូអីហេ??

ខ:គាត់មើលដូចយាយញ៉ុមនឹងដែរ!!គាត់តែងមក
ញ៉ុមមកកន្លែងផ្ទះគាត់អ៊ុចឹងនៅស្ទើរៗអីអ៊ុចឹងម៉ែញ៉ុមផ្ទើរអីអ៊ុចឹង
គាត់ត្រូវចេញទៅរកស៊ីអីអ៊ុចឹងទៅ!!ផ្ទើរយាយហ្នឹងមើលអ៊ុចឹងទៅ។

ក:ហ៊ីៗ!!ពូស្រលាញ់យាយខ្លាំងដែរហ្នឹងហេ??តែឥឡូវគាត់បានអនិច្ចាកម្មហើយហើយ?

ខ:អនិច្ចាកម្ម។

ក:នៅក្មេងជំនាន់ប៉ុល ពត ហិអត់ ឥឡូវៗហ្នឹងទេហី??

ខ:ឥឡូវៗហ្នឹងស្លាប់យើងឆ្នាំ ប្រហែលជា១០ឆ្នាំហើយ។

ក:អ៊ុចឹង២០០៨គាត់ស្លាប់?

ខ:បាទ!!

ក:ពេលគាត់ស្លាប់ហ្នឹងអាយុប៉ុន្មានវិញពូ?

ខ:អាយុអើរសុទ្ធតែអាយុច្រើនៗដែរហើយគាត់។ក:ចា!!ខ:គាត់៩០ ៨០អីហើយហើយអាយុចាស់ៗ!!

ក:ហ្ហ៎តែអោយឆ្នាំប្រាកដមានម៉ងប្រាកដម៉ងហាប៉ុន្មានអាយុប៉ុន្មានវិញពូចាំទេ?

ខ:អត់បានចាំទេអ្នកគ្រូ !!

ក:ចា៎អត់អីទេអ៊ុចឹង!!អ៊ុចឹងហ្នឹងអើយអរគុណច្រើនលោកពូសំរាប់ការសំភាសន៍អំពីជីវិតរបស់លោកពូអ៊ុចឹងហ៎!!ខ:បាទ!!ក:តែអ្វីទាំងអស់កូនចៅរបស់លោកពូនឹងបានស្តាប់ពីជីវិតដូនតារបស់លោកពូហ្នឹង ចា៎អ៊ុចឹងរាល់ថ្ងៃហ្នឹងពូនៅឃុំរកាខ្ពស់ហ្នឹងហេ?

ខ:បាទបាទ!!

កៈនៅកោះគរហ្នឹង?

ខៈហ្នឹងហើយ។

កៈអ៊ីចឹងដូនតាហាប្អក់កូនចៅអីចង់ដឹងគឺជីវិតរបស់ពូ គឺគាត់នៅឃុំរកាខ្ពស់នេះទាំងអស់!!

ខៈបាទបាទ!!

កៈចាំអ៊ីចឹងអរគុណច្រើនសំរាប់អោយសំភាសន៍។

ខៈបាទបាទ។